D119537 DC-Cam

# សំភាសន៍ជាមួយ លោក ស្មាន កាជិ ភូឈ្មួយហាកិម

# ភូមិទី៥ ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម

# ដោយ កុសល្យ សូរិយា ឧស្មាន

# នៅថ្ងៃទី ១៣-វិច្ឆិកា-១៩៩៩

ស- សូមសួររឿងវិហារយ៉ាងម៉េចដែរ ?

ឆ- វិហារនោះ ក្រោយពីពួកខ្ញុំជំលៀសទៅនោះ មិនដឹងជាវារុះនៅម៉ោងណាពេលណាខ្ញុំក្តាប់អត់បានទេ ព្រោះខ្ញុំចេញផុតហើយ ។

ស- នៅចុងឆ្នាំ ១៩៧៤ វិហារនៅឬទេ ?

ឆ- នៅ

ស- អំពីស៊ូរ៉ាវមុនឆ្នាំ ១៩៧៥ មានប៉ុន្មាន ?

ឆ- ស៊ូរ៉ាវមានពីរ ហើយសាលារៀនមានពីរ ។

ស- ហើយក្រោយឆ្នាំ ១៩៧៩ ឃើញយ៉ាងម៉េចដែរ ?

ឆ- ក្រោយឆ្នាំ ១៩៧៩ ឃើញទទេរ គ្មានអ្វីទេ ។

ស- កាលពីប្រជាជនយើងធ្វើការបះបោរ ពេលនោះអ៊ុំនៅទីនេះដែរឬអត់ទេ ?

ឆ- ខ្ញុំនៅទីនេះ ហើយអ្នកនៅទីនេះសុទ្ធតែជាមេបះបោរហ្នឹងហើយ ។

ស- កំលាំងបះបោរមានប៉ុន្មាននាក់ ?

ឆ- ទាំងអស់គ្នា គឺនាំគ្នាបះបោរមួយភូមិតែម្តង ហើយមានអ្នកខ្សោយៗខ្លះពួនដែរ ។

ស- រាប់ឈ្មោះមេដឹកនាំ ៣-៤ នាក់ មើល ?

ឆ- កាលនោះ មានមេប្រហែលជា ២០ នាក់ ហើយពួកយុវជនជាអ្នកចាប់ផ្តើមធ្វើការបះបោរនោះ ។

ស- អញ្ចឹងក្នុងឆ្នាំ ១៩៧៣-៧៤ អ៊ុំនៅទីនេះទេ ?

ឆ- នៅទីនេះរហូតដល់គេជំលៀសនៅឆ្នាំ ១៩៧៥ ។

ស- អ៊ុំបានចូលរួមក្នុងសកម្មភាពនោះទេ ?

ឆ- បាទ ចូលរួម ។

ស- ហេតុអ្វីបានជាធ្វើការបះបោរ ?

ឆ- ដោយសារគោលការណ៍វាត្រូវចាប់មនុស្សបន្តទៀតជាង ៨០ នាក់ ដឹងថាវាចាប់ផ្តើមចាប់មនុស្សជាង ៨០នាក់នេះហើយ ហើយម៉ោង ៦ ល្ងាច វាទើបតែចាប់បានពីរនាក់ យើងក៏ចាប់ផ្តើមបះបោរតែម្តង ។

ស- យើងដឹងដំណឹងនេះតាមរយៈអ្វីដែរ ?

ឆ- បងប្អូនទាំងអស់ដែលដឹង អត់មានដឹងបន្តពីអ្នកណាទេ ។

ស- តើខ្មែរក្រហមចាប់បងប្អូនខ្មែរដែរឬអត់ទេ ?

ឆ- អត់ទេ ចាប់តែចាម ។

ស- ឮថាចាប់នេះ ឮពីខាងណា ពីគណៈឃុំ ឬតំបន់ ?

ឆ- ឮពីគណៈឃុំ ។

ស- មានស្គាល់ឈ្មោះគណៈឃុំនោះទេ ?

ឆ- ឈ្មោះដូចខ្ញុំអានអំបាញ់មិញនោះឯង ។

ស- ហើយចុះស្រុក ចៅហ្វាយស្រុក ?

ឆ- ខ្ញុំអត់មានស្គាល់ទេ ។ ការដែលវាចាប់មនុស្សនៅភូមិនេះ វាចាប់អ្នកណាដែលធូរធា មានកេរ្តិ៍ឈ្មោះ ដូចជាអ្នកមាន ឬក៏អ្នករាជការចាស់ៗពីដើមមក ខ្ញុំមិនដឹងជាហេតុផលអ្វីទេដែលគេចាប់ទៅនោះ ។ គោលការណ៍ដែលគេចាប់ជំនាន់នោះ ភូមិនេះហើយដែលវាចាប់ខ្លាំងជាងគេ បានជាមានការបះបោរនោះ ។

ស- កាលជំនាន់ ១៩៧៣-៧៤ អ៊ុំមានស្គាល់មេខ្មែរក្រហមទេដែលមកចាប់យើងនោះ ?

ឆ- ឈ្មោះដូចខ្ញុំអានរួចនោះហើយ ប៉ុន្តែត្រង់មានបញ្ជារពីណាមក ខ្ញុំអត់ដឹងទេ ។

ស- ឈ្មោះអ្វីដែរ ?

ឆ- មេនៅទីនេះឈ្មោះតាឡុង តាឡុងងាប់ហើយ ហើយបន្ទាប់មកអនុឃុំ តាយ៉េង ងាប់ហើយដែរ បន្ទាប់មកតាញឹក ក៏ងាប់ហើយដែរ គឺអ្នកធ្វើការឃុំនេះងាប់អស់ហើយ ។

ស- ចុះអ្នកនៅរស់ ?

ឆ- អ្នកនៅរស់គ្មានទេ ។ មានតែមេឃុំចាស់ដូចជាតាថុល ហើយតាប៉ែត នៅរស់ ។

ស- ចុះអ្នកដឹកនាំការចាប់នោះស្លាប់អស់ហើយឬនៅ ?

ឆ- អស់ហើយ ។

ស- ពេលបះបោរមានអាពតស្លាប់ប៉ុន្មាននាក់ ?

ឆ- ខ្ញុំក្តាប់អត់បានទេ ប៉ុន្តែដឹងថាមានស្លាប់ខ្លះ យើងគ្មានសិទ្ធិចេញពីភូមិទេ ហើយដល់យើងចាញ់គេ គេក៏ជំលៀសអត់ហ៊ានងាកមើលខាងណាទេ ។

ស- ចុះកំលាំងអាពតមកព័ទ្ធយកពីខាងណាមក ?

ឆ- កំលាំងនិរតី ។

ស- ចុះខាងចាមយើងមានស្លាប់ច្រើនទេ ?

ឆ- ពេលនោះស្លាប់ច្រើន ។

ស- ខ្ញុំសុំបញ្ជាក់សួរម្តងទៀត តើមានមូលហេតុអ្វីផ្សេងទៀត ដែលពួកគេចាប់បងប្អូនចាមយើង ?

ឆ- ខ្ញុំអត់ដឹង គឺអត់ដឹងទាំងអស់គ្នាហ្នឹង ប៉ុន្តែគ្រាន់តែដឹងសភាពការណ៍ថា យប់នេះមានផែនការគេចាប់មនុស្សក្នុងភូមិ រឿងនោះគឺដឹងតាមរយៈតាថុលនោះហើយដែលគាត់ប្រាប់ ប្រាប់ថាមានសភាពការណ៍អត់ល្អទេនៅយប់នេះ ។ ដូច្នេះ យើងវាយស្មានថា សភាពការណ៍នេះមិនធម្មតាទេ ហើយសភាពការណ៍មិនស្រួលជំនាន់នោះ ដូចដឹងស្រាប់

ហើយ ។ ផ្ទះបិទទ្វារទាំងអស់ គ្មានអ្នកណាហ៊ានយំ គ្មានអ្នកណាហ៊ានស្រែកអ្វីទេ ដល់យប់ឡើងពន្លត់ចង្កៀងចូលដេករៀង១ខ្លួន ។

ស- ( ស្តាប់មិនច្បាស់ ) ?

ឆ- រឿងរ៉ាវនៃការចាប់នោះ ខ្ញុំមិនដឹងទាំងអស់ ពេលនោះខ្លួនខ្ញុំផ្ទាល់គេចោទថា ខ្ញុំពាក់សាក់ ៣ ស៊ីប្រាក់ខែ ៨ 000 រៀល ខ្ញុំមិនដឹងទទួលប្រាក់ខែនោះតាមរយៈណាទេ ខ្ញុំអត់ដឹងទេ នោះគឺជាការចោទប្រកាន់តែម្តង ។ អញ្ចឹងខ្ញុំនេះមានតំលៃណាស់ ដែលរស់មកដល់សព្វថ្ងៃនេះ ។

ស- រាល់ការចាប់ខ្លួន តើមានអ្នកណាក្រៅពីគណៈឃុំទេ ដែលមកចាប់មនុស្សនោះ ?

ឆ- ខ្ញុំអត់ដឹង ។ ពួកគណៈឃុំនោះសុទ្ធតែមកពីនិរតី ឯយើងនៅភូមិនេះអត់មានដឹងអ្វីទេ ។

ស- ហេតុអ្វីបានជាដឹងថា ពួកនោះមកពីនិរតី ?

ឆ- ព្រោះយើងមិនដែលស្គាល់គេពីមុនមកទេ បើអ្នកស្រុកនេះយើងស្គាល់អស់ហើយ ។

ស- អ្នកភូមិនេះជំលៀសចេញទាំងអស់ឬ ?

ឆ- ទាំងអស់អត់មានសល់ទេ ។ ពេលនោះ ម្នាក់១គិតតែពីប្រាស់យករួចខ្លួន បើអ្នកណាប្រាស់បានទៅក៏រួចខ្លួនទៅ បើមិនបានគឺស្លាប់ ។

ស- តំបន់នេះ គេហៅថាតំបន់អ្វីដែរ ?

ឆ- តំបន់ ២១ ។

ស- ក្រោយមក អ្នកណាជំលៀសមកនៅភូមិនេះវិញ ពេលយើងចេញអស់ទៅនោះ ?

ឆ- មិនដឹងជាគេជំលៀសពីណាមកទេ យកមកដាក់ទីនេះអត់មានចាមទេ សុទ្ធតែខ្មែរ ពួកយើងចេញអស់ទៅ គេជំលៀសខ្មែរមកដែរ ប៉ុន្តែជំលៀសពីណាពីណីមក យើងអត់ដឹងទេ ។ ឆ្នាំ ១៩៧៩ ពេលយើងត្រឡប់មកវិញ ពួកគេមិនទាន់ចេញទេ យើងនិយាយសំរុះសំរួលគ្នាទៅ គេក៏ទៅវិញអស់ទៅ ។

ស- ពេលដែលគេជំលៀសទៅនោះ មានយកអ្វីទៅតាមយើងដែរឬក៏អត់ទេ ?

ឆ- អត់ទេ មានតែមនុស្សទទេ ។

ស- ចុះយ៉ាងម៉េចដែរអំពីការប្រមូលគម្ពីកួរអានផ្សេង១ ?

ឆ- អាហ្នឹងវាប្រមូលដោយឡែក វាមិនប្រមូលជាមួយមនុស្សទេ ។

ស- ដឹងអំពីការប្រមូលនោះទេ ?

ឆ- ដឹងព្រោះគេប្រមូលគ្រប់ផ្ទះ មិនអោយនៅសល់ទេ ។ ការប្រមូលនោះ គឺមុនបះបោរគេប្រមូល កាំបិត ផ្គាក់ យកទៅដាក់នៅព្រំប្រទល់ភូមិ គេអោយទុកតែតាំងតោវះត្រឹមួយ ការប្រមូលនេះ គេមិនមកប្រមូលផ្ទាល់ទេ គឺគេប្រើយើងអោយយកទៅដាក់ខ្លួនឯង ។

ស- តើមានអ្នកណាបដិសេធន៍មិនអោយដែរឬទេ ?

ឆ- អត់ទេ អត់ហ៊ានទេ ។

ស- គេប្រមូលអ្វីខ្លះ ?

ឆ- ប្រមូលកាំបិត ពូថៅ ផ្គាក់ ហើយនិងគម្ពីរកូរអាន គេអត់មកប្រមូលខ្លួនឯងទេ គេមកប្រើចាមដូចគ្នាដេលធ្វើការនៅសហករណ៏ អោយប្រមូល ។

ស- ប្រជាជនគេយកទៅខាងណា ?

ឆ- គេយកទៅដាក់នៅ ឡូថ្នាំ វត្ត សាលារៀន ក្នុងរយៈពេល ២៥ ថ្ងៃ ។

ស- ពេលទៅដល់កន្លែងនោះ គេមានអោយធ្វើអ្វីខ្លះ ?

ឆ- អត់អោយធ្វើអ្វីទេ នៅដេកស្ងៀម ពេលមុជទឹកគេបណ្ដើរម្ដងបីនាក់ៗ គ្រាន់តែងាកមើលមុខគេក៏មិនបានដែរ ហើយមុជទឹកមួយភ្លឹបរួចមកវិញ គេអោយមកចូលកន្លែងដើមវិញ ។

ស- នៅកន្លែងនោះមានគេសួរអ្វីទេ ?

ឆ- គេសួរ គេស្រាវជ្រាវថាពីសង្គមធ្វើអ្វី នៅឯណា យើងជាអ្នករាជការចាស់ឬយ៉ាងម៉េច មានពាក់ព័ន្ធអ្នកដែលគេចាប់មុននោះដែរឬក៏អត់ ដូច្នេះយើងចេះតែភូតកុហកតាមហ្នឹងទៅ ។

ស- គេមកសួរប៉ុន្មានដង ?

ឆ- សួរច្រើនណាស់ ក្នុងរយៈពេល ២៥ ថ្ងៃនោះគេសួររហូត ។

ស- គេដាក់អោយនៅយ៉ាងម៉េច ?

ឆ- គេអោយនៅក្នុងបន្ទប់ ។

ស- មានគ្នាច្រើនឬតិច ?

ឆ- មានច្រើនណាស់ ខ្ទង់រាប់រយនាក់ ។

ស- ចាមទាំងអស់ឬ ?

ឆ- សុទ្ធតែចាមទាំងអស់ អត់មានលាយទេ ។

ស- តាមស្មានប្រហែលជាប៉ុន្មាននាក់ ?

ឆ- តាមកន្លែងនីមួយៗ មានគ្នា ១០០ ឬ ជាង ១០០ នាក់ ហើយមានច្រើនកន្លែងណាស់ ។

ស- នៅក្នុងបន្ទប់លោកអ៊ុំនៅនោះ បន្ទាប់ពីគេសួរ តើមានគេរើសយកបន្តទៀតទេ ?

ឆ- មានឈ្មោះគេស្រាប់ ដូចជាក្នុងសៀវភៅបញ្ជីគេ គេមានឈ្មោះហ្នឹង ហើយគេដើររកឈ្មោះហ្នឹងទៅ ដូចគេហៅប៉ះឈ្មោះប្អូនឯង ហើយគេយកចេញទៅ មិនដឹងបញ្ជីនោះគេស្រង់មកពីខាងណាមកទេ ស្រាប់តែឃើញបញ្ជីនៅដៃគេ ។

ស- បញ្ជីនោះនៅជាមួយអ្នកណា ?

ឆ- នៅជាមួយពួកខ្មែរក្រហម ។

ស- អ្នកនោះឈ្មោះអ្វី ?

ឆ- អត់ដឹងទេ ។

ស- ដល់ពេលគេហៅឈ្មោះតាមបញ្ជីនោះ គេមានសួរអ្វីផ្សេងទៀតទេ ?

ឆ- អត់ទេ ដល់ពេលគេហៅរួច គេមិនសួរអ្វីផ្សេងទៀតទេ ជួនណាគេហៅច្រឡំដែរ ដូចថាខ្ញុំឈ្មោះជិ ដល់ពេកគេហៅថាឈ្មោះជីក អញ្ចឹងខ្ញុំឆ្លើយថា ខ្ញុំនេះឈ្មោះជិទេ មិនមែនជីកទេ ។

ស- នៅក្នុងមន្ទីរឃុំឃាំងគេបានធ្វើទារុណកម្មអ្វីខ្លះ ?

ឆ- គេអត់ធ្វើអ្វីទេ ប៉ុន្តែគេអោយស៊ីដោយពិបាក គឺស៊ីបបរ ។

ស- តើគេមានវាយជំទេ ?

ឆ- វាយដែរ បើអ្នកណាមមើរឬក៏យល់សប្តិស្រែកពេលយប់ហ្នឹងគេវ៉ៃហើយ ។

ស- តើគេអោយសំពះយ៉ាងទេ ?

ឆ- អត់ទេធ្វើមិនបានទេ ។

ស- តើគេប្រាប់យើងថាយ៉ាងម៉េចខ្លះ ?

ឆ- គេប្រាប់ថារឿងសាសនាគេមិនអោយជឿទេ សាសនាគឺពុករលួយ គេថាមហាម៉ាត់នេះជាអ្នកប្រតិកិរិយា មហាម៉ាត់គឺព្រះចាមហ្នឹងឯង ។

ស- ពេលគេហៅឈ្មោះគេហៅយ៉ាងម៉េច ?

ឆ- គេហៅឈ្មោះ រួចគេយកទៅ យកទៅនោះគឺយកទៅសំលាប់តែម្តង ?

ស- ហេតុអ្វីបានជាអ៊ុំដឹងថាគេយកទៅសំលាប់ ?

ឆ- ដឹង ព្រោះគេសំលាប់នៅក្រោយសាលានោះហើយ ហើយឮស្រែកនៅក្បែរនោះផង ។

ស- ឮញឹកញាប់ទេ ?

ឆ- ក្នុងរយៈពេល ២៥ ថ្ងៃ សឹងតែគ្រប់ថ្ងៃ គេយកចេញពីក្នុងនោះខ្លះ និងយកពីក្រៅខ្លះ ឮគ្រប់ថ្ងៃក្នុងរយៈពេល២៥ ថ្ងៃ ។

ស- ពេលគេយកទៅនោះរយៈពេលប៉ុន្មានដែរបានឮស្រែក ?

ឆ- មិនយូរទេ រយៈកាលកន្លះម៉ោងឬអស់យូរមួយម៉ោង ។

ស- បន្ទាប់ពីរយៈពេល២៥ថ្ងៃហើយនោះ នៅសល់មនុស្សប៉ុន្មាននាក់ដែលគេជំលៀសបន្តរទៀតនោះ ?

ឆ- កាលនោះអត់ចាំទេ អត់បានរាប់ទេ ដេកតែពីព្រួយពិបាកចិត្តរាល់ថ្ងៃ អត់មានគិតគូររាប់គ្នាថានៅសល់ប៉ុន្មាន គឺអត់មានទេ ដឹងតែពីគេចាប់ទៅតែម្តង ។

ស- មេដែលគេមកហៅទៅនោះ បើនៅ នៅចាំមុខទេ ?

ឆ- បើនៅ ចាំ ។

ស- មាននៅចាំឈ្មោះទេ ?

ឆ- មានឈ្មោះភេទពីរនាក់ ហើយសារឿនម្នាក់ ។

ស- អ៊ុំដែលឃើញបញ្ជីគេទេ ?

ឆ- អត់ដែលឃើញទេ អត់មានឃើញបញ្ជីគេទេ គេលាក់ការណ៍តែម្តង កាលណោះយើងអត់មានដឹងអ្វីទាំងអស់ ផែនការគេ បើយើងចង់ដឹងមិនបានទេ ឧបមាថាគេចាប់កូនខ្ញុំទៅ ខ្ញុំសួរថាហេតុអ្វីបានជាចាប់កូនខ្ញុំទៅ គេថាមិនបាច់សួរអីទេ អង្គការភ្នែកម្នាស់ ។

ស- ពេលគេសួរ តើគេយកទៅសួរនៅខាងក្រៅឬយ៉ាងណា ?

ឆ- អត់ទេ ដល់ពេលគេបើកទ្វារមក គេហៅឈ្មោះយើង ហើយគេសួរយើងថាមានឈ្មោះនេះទេ គេមិនបានហៅទៅសួរនៅខាងក្រៅទេ ។

ស- ខ្ញុំក៏ចង់ដឹងដែរមេដឹកនាំសាសនាមុនឆ្នាំ ១៩៧៥ មានប៉ុន្មាននាក់ ?

ឆ- អ្នកដឹកនាំសាសនាមាន រ៉េស តាំ ជាហាកិម កក់ លី និង ឃុត សុះ ឯម្ខាងទៀតមាន កិមទូល័ស គាត់ក៏ជាហាកិមដែរ ។ ហើយបើប្រធានភូមិមាន ជំទប់សា ។

ស- ហើយចំពោះតួនមានប៉ុន្មាននាក់ ?

ឆ- ចំពោះតួនមាន ហាកិមតាំនោះក៏ជាតួន តួនហ៊ុម តួនស្លែម៉ាន តួនលី មូសា ។

ស- ក្នុងចំណោមតួនទាំងអស់នេះ តើមានតួនណាមកពីស្រុកក្រៅទេ ?

ឆ- មានលី មូសា មកពីអេហ្ស៊ីប ។

ស- ចំពោះនិស្សិតមានទេ ?

ឆ- និស្សិតអត់មានទេ ។

ស- អ្នកដឹកនាំសាសនានោះ តើពួកខ្មែរក្រហមបានធ្វើអ្វីខ្លះទៅលើពួកគេ ?

ឆ- គឺគេជ្រើសរើសយកតាមគំរោងគេ គឺគេអោយយកអ្នកចេះដឹងតែម្តង យកទាល់តែអស់ ។

ស- នៅឆ្នាំណា ?

ឆ- តាំងពីឆ្នាំ ១៩៧៣ ពួកខ្មែរក្រហមយកទៅអស់មែន ។

ស- ក្រោយឆ្នាំ ១៩៧៩ តើអ្នកដឹកនាំសាសនាសំខាន់ៗមានលាក់ខ្លួនបានរស់នៅរហូតដល់សព្វថ្ងៃនេះទេ ?

ឆ- អត់មានទេ ស្លាប់តាំងពី ៧៣ ដល់ ៧៤ គឺអស់រលីង អ្នកទាំងនោះអត់ទាន់មានបះបោរនឹងគេទេ គឺស្លាប់ដោយគេយកទៅសំលាប់តែម្តង ។

ស- មុននឹងគេយកទៅគេចោទថាយ៉ាងម៉េច ?

ឆ- អត់មានថាអីទេ គេយកទៅតែម្តង គេហៅចុះពីលើផ្ទះ បើពាក់អីទៅនោះតែម្តង អត់មានសួរហេតុផលអ្វីទេ ។

ស- នៅពេលជាមួយគ្នានោះ ភូមិនៅជិតខាងយើងដែលជាភូមិខ្មែរ តើពួកខ្មែរក្រហមគេធ្វើយ៉ាងម៉េចខ្លះ កាលឆ្នាំ ១៩៧៣-៧៤ នោះ ?

ឆ- គេក៏ចាប់យកដែរ គឺគេរើសយកអ្នកមាន ។

ស- បន្ទាប់ពីគេឃុំឃាំងរួចហើយ គេយកទៅខាងណាទៀត ?

ឆ- យកទៅតំបែ ឬយកទៅខាងផ្សេងៗទៀត ។

ស- ចំពោះអ៊ុំផ្ទាល់គេយកទៅខាងណា ?

ឆ- ខ្ញុំគេបញ្ជូនអោយទៅនៅខាងស្ទឹងត្រង់ នៅភូមិសូភាសទី ១ សង្កាត់សូភាស ស្រុកស្ទឹងត្រង់ ។

ស- គេអោយធ្វើអ្វីខ្លះ ?

ឆ- ធ្វើការនៅក្នុងសហករណ៍គេនោះ គេប្រើដូចជាភ្ជួរដី រាស់ដី ។

ស- មុនគេជំលៀសទៅគេប្រាប់ថាយ៉ាងម៉េចខ្លះ ?

ឆ- គេថាអោយត្រៀមខ្លួន ថ្ងៃប៉ុណ្ណេះៗគេមកយកអោយទៅនៅបាត់ដំបង ទៅធ្វើស្រែនៅកន្លែងនោះ ព្រោះវាមានស្រែច្រើន ដល់ពេលទៅគេអោយទៅនៅស្ទឹងត្រង់ ។ ពេលទៅដល់ប្រធានសហករណ៍គេរំលែកតែម្តង គេថាយកអ្នកនេះទៅភូមិនេះ យកអ្នកនោះទៅភូមិនោះ ។

ស- យកទៅដាក់នៅភូមិខ្មែរឬភូមិចាម ?

ឆ- ភូមិខ្មែរទាំងអស់ អត់មានភូមិចាមទេ ហើយនៅទីនោះគឺនៅក្រោមផ្ទះគេ នៅកន្លែងជង្រុកស្រូវគេ នៅរោងចំប៉ើងគេ គ្មានផ្ទះអោយនៅទេ ។

ស- ប្រហែលជាមានជនជាតិចាមប៉ុន្មាននាក់ដែរនៅក្នុងសហករណ៍ ?

ឆ- ខ្ញុំអត់ដឹងដែរ ជួបគ្នាដែរតែមិនបានកត់ចំនួនទេ ឬក៏រាប់ចំនួននោះប៉ុន្មានដែរ ប៉ុន្តែមានច្រើនដែរ ដូចជានៅភូមិប៉ប្រេក ភូមិសាមគ្គី ភូមិសូភាស ភូមិជ្រៃ ។

ស- ការហូបចុកយ៉ាងម៉េចដែរ ?

ឆ- គេអោយស៊ីនៅរោងបាយដូចជាខ្មែរអញ្ចឹងដែរ គឺហូបរួម ។

ស- ហើយម្ហូបគេមានដាក់សាច់ជ្រូកទេ ?

ឆ- គេអោយស៊ីសាច់ជ្រូក គេបង្ខំអោយស៊ីសាច់ជ្រូក ។

ស- ចុះយើងមានញ៉ាំទេ ?

ឆ- ញ៉ាំ បើយើងមិនញ៉ាំដាច់ពោះស្លាប់ ។

ស- ចុះមានអ្នកណាបដិសេធន៍ទេ ?

ឆ- បើបដិសេធន៍គេអោយសិស្សនិងគ្រូតាមដានយើង បើអ្នកណាមិនហូបអ្នកនោះត្រូវព្រនង់ ។

ស- នៅឆ្នាំណា ?

ឆ- ឆ្នាំ ១៩៧៧ យើងរស់នៅសហករណ៍ ។

ស- មានចាំខែច្បាស់ទេ ?

ឆ- អត់ទេ ។

ស- ដំបូងគេថាយកទៅបាត់ដំបង ចុះមូលហេតុអ្វីបានជាគេអោយទៅនៅស្ទឹងត្រង់វិញ ?

ឆ- អត់ដឹងទេ អាហ្នឹងរឿងគេ ។

ស- ចុះមកដល់ឥឡូវ បើមានអ្នកច្បាប់មកសួរនាំ អ៊ុំហ៊ានផ្តល់ចំលើយនេះជាការពិតទេ ?

ឆ- រឿងអីថាមិនហ៊ាន ឯកសារនេះខ្ញុំកត់ទុក ចាំឆ្លើយអ្នកណាមកសួរខ្ញុំ ។

ស- អ៊ុំសុំបញ្ជាក់ឈ្មោះម្តងទៀត ហើយអ៊ុំមានមុខងារជាអ្វី ?

ឆ- ខ្ញុំឈ្មោះ ស្មាន កាជិ មុខងារផ្នែកសាសនាគឺអនុហាកិម ផ្នែកការងាររដ្ឋអំណាច ខ្ញុំសាខាបក្សភូមិ ខ្ញុំអាយុ ៥៥ ឆ្នាំ នៅភូមិទី ៥ ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ។

ស- បាទ ខ្ញុំសូមអរគុណច្រើន ។